# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible] សហវ.....

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០១៦

**គោរពជូន**

**-ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**-ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត**

**កម្មវត្ថុ** : សំណើចាត់វិធានការដើម្បីពង្រឹងការអនុវត្តសៀវភៅបន្ទុកភាស៊ីគ្រប់ប្រភេទ តាមដែនសមត្ថកិច្ចទទួលខុសត្រូវ ។

**យោង** : សារាចរណែនាំលេខ ០០៤សហវ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្ដមអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត មេត្តាជ្រាបថា កន្លងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្កេតឃើញថា ការអនុវត្តលិខិតបទដ្ឋានរបស់សាលារាជធានី ខេត្ត ក្នុងការគ្រប់គ្រងអាជីវកម្ម សេវាកម្មទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដូចជា ផ្សារ កំពង់ចម្លង ចំណត យៀត្រី សត្តឃាតដ្ឋាន សេវាប្រមូលសំអាត និងដឹកជញ្ជូនសំរាម និងការផ្ដល់សម្បទានរបស់រដ្ឋដទៃទៀត បានប្រព្រឹត្តទៅមានភាពល្អប្រសើរ និងមានការទទួលខុសត្រូវខ្ពស់ ដោយសាលារាជធានី ខេត្ត បានបង្កើតគណៈកម្មការ និងអនុគណៈកម្មការស្រុក ក្រុង ខណ្ឌ សម្រាប់ការត្រួតពិនិត្យ ការអនុវត្តសៀវភៅបន្ទុក ឬកិច្ចសន្យា ដោយបានចុះផ្សព្វផ្សាយណែនាំលើវិស័យសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មានការបិទផ្សាយតម្លៃភាស៊ី និងការដោះស្រាយជាបន្តបន្ទាប់បាតុភាពនានា ស្របតាមសារាចរណែនាំលេខ ០០៤ សហវ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៤ ។

ទន្ទឹមនឹងការខិតខំដូចបានជម្រាបជូនខាងលើ ក៏នៅមានកើតឡើងនូវបាតុភាពមួយចំនួនពីការផ្ដល់សេវា និងការអនុវត្តសៀវភៅបន្ទុក ឬកិច្ចសន្យា ដែលធ្វើឱ្យមានការតវ៉ាពីអាជីវករលក់ដូរ ប្រជាពលរដ្ឋដែលទទួលសេវាពីការផ្ដល់សេវាកម្មទាំងនោះជាបន្តបន្ទាប់ បណ្ដាលឱ្យប៉ះពាល់ដល់ការគ្រប់គ្រងរបស់សាលារាជធានី ខេត្ត។

ដើម្បីពង្រឹងការគ្រប់គ្រងការផ្ដល់សេវាសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ប្រកបដោយការទទួលខុសត្រូវខ្ពស់ និងមានប្រសិទ្ធភាព ជៀសវាងការកើតចេញបាតុភាពជាយថាហេតុទៀតនោះ ខ្ញុំសូមឯកឧត្ដមអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត មេត្តាបន្តចាត់វិធានការបន្ថែមទៀត ដូចជា ការដាក់ស្លាកតម្លៃភាស៊ី ការប្រើប្រាស់ប័ណ្ណភាស៊ី ការសំអាតអនាម័យ ការបំពាក់ឯកសណ្ឋាន និងការរៀបចំសណ្ដាប់ធ្នាប់ឱ្យមានរបៀបរៀបរយ ។ល។ ស្របតាមសៀវភៅបន្ទុក ឬកិច្ចសន្យាភាស៊ីគ្រប់ប្រភេទដែលបានកំណត់ ។ ទន្ទឹមនេះត្រូវចាត់ចែងឱ្យមានការចុះត្រួតពិនិត្យដោះស្រាយជាប្រចាំ រាល់បាតុភាពនានាដែលកើតឡើងជាយថាហេតុ នៅកន្លែងដែលផ្ដល់សេវាសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទាំងនោះ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្ដមអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ទទួលចាត់ចែងអនុវត្ត តាមការគួរ ។

សូមឯកឧត្ដមអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ទទួលនូវការគោរពរាប់អានពីខ្ញុំ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

<u>ចម្លងជូន:</u>

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- គ្រប់សាលាក្រុង ខណ្ឌ ស្រុក
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុគ្រប់ខេត្ត រាជធានីភ្នំពេញ
- មន្ទីរសាធារណការ និងដឹកជញ្ជូនគ្រប់ខេត្ត រាជធានីភ្នំពេញ
- មន្ទីរកសិកម្មគ្រប់ខេត្ត រាជធានីភ្នំពេញ
- ឯកសារ-កាលប្បវត្តិ